# Living the Lotus

Buddhism in Everyday Life

New Year's Issue

2022


*New Year's Message*

## ចូររស់នៅដោយរីករាយ


ព្រះប្រធានរីស្ហូកូសេកៃ

ព្រះគ្រូនីវ៉ាណូ និជីកុ


《នៅពេលដែលពិភពលោកទាំងមូលគ្មានសេចក្ដីសុខទេ, បុគ្គលមួយរូបៗក៏គ្មានសេចក្ដីសុខដែរ។》



សួស្ដីឆ្នាំថ្មី !

ឥទ្ធិពលអាក្រក់នៃកូវីដ-១៩បានជះយ៉ាងខ្លាំងមកលើជីវភាពរស់នៅរាល់ថ្ងៃនៃយើងទាំងអស់គ្នាតាំងពី២ឆ្នាំមុនមកម្ល៉េះ។ថ្មីៗនេះចំនួនអ្នកដែលបានឆ្លងកូវីដ-១៩នៅប្រទេសជប៉ុនស្រាប់តែបានធ្លាក់ចុះទាបយ៉ាងលឿនបំផុត។ ក៏ប៉ុន្តែនៅប្រទេសខ្លះទៀតចំនួនអ្នកឆ្លងបានកើនកាន់តែច្រើនឡើងៗ។ដូច្នេះយើងទាំង ឡាយមិនត្រូវធ្វេសប្រហែសឡើយ ត្រូវតែខិតខំការពារជានិច្ចជាកាលកុំឱ្យឆ្លង។

ដោយសារតែសមាជិកនៃសមាគមរីស្ហូកូសេកៃរបស់យើងធ្លាប់តែមានសមានចិត្តចំពោះអ្នកដទៃស្រាប់ទៅហើយ ទោះជាព្រះវិហារបិទទ្វារក្ដី  ក៏គេទាំងឡាយនៅតែទូរស័ព្ទឬផ្ញើសំបុត្រ ឬអ៊ីមែលធ្វើទំនាក់គ្នាទៅវិញទៅមកមិនដាច់។ខ្ញុំព្រះករុណាអាត្មាភាពមិនអាចធ្វើអ្វី ក្រៅពីបង្ហាញនូវសេចក្ដីគោរពចំពោះអ្នកទាំងនេះតែប៉ុណ្ណោះទេ។

ខ្ញុំព្រះករុណាអាត្មាភាពបានជំរាបម្ដងរួចមកហើយថា គ្រោះមហន្តរាយកូវីដ-១៩នេះ ជាឱកាសឬជានិស្ស័យសម្រាប់ឱ្យយើងរាល់គ្នាតណ្ដឹងសួរខ្លួនឯងនឹងគិតថាតើអ្វីទៅដែលសំខាន់ពិតប្រាកដដែលយើងត្រូវតែវាយតម្លៃខ្ពស់បំផុតសម្រាប់មនុស្សជាតិនោះ។

យើងមិនត្រូវភ្លេចពីសមានចិត្តគិតដល់អ្នកដទៃឡើយថា នៅពេលដែលកូវីដ-១៩រាលដាលនេះ「តើគេសុខសប្បាយឬទេ?」 「តើជីវភាពគេមិនពិបាកទេឬអ្វី?」,「តើកុមារទាំង ឡាយមិនមានបញ្ហាអ្វីទេឬ?」។សមានចិត្តនេះគឺជា

ទឹកចិត្តដ៏សំខាន់បំផុតនៃភាពជាមនុស្ស ។ យើងគួរតែដុសខាត់ទឹកចិត្តនេះឱ្យកាន់តែរលើបរលោង ហើយក្រៅពីការងារដុសខាត់ចិត្តគំនិតនេះ មានអ្វីជាច្រើនដែលយើងមិនចាំបាច់នឹងធ្វើក៏បាន។

「អ្វីដែលមិនចាំបាច់នឹងធ្វើ」 នេះខ្ញុំព្រះករុណាអាត្មាភាពធ្លាប់បាននិយាយម្តងហើយថា នៅក្នុងភាសាជប៉ុនគេយកអក្សរចិន 「省」(shou) មកប្រើ ដែលមានន័យពីរ។មួយគឺមានន័យថា កាត់ចោលឬលុបចេញ មួយទៀតមានន័យថា ពិចារណាជាថ្មីឡើងវិញពីអ្វីដែលបានធ្វើមកហើយ។ ឆ្លងកាត់តាមរយៈពេលពីរឆ្នាំដែលគ្រោះមហន្តរាយកូវីដ-១៩ចូលមករាតត្បាត យើងទាំងអស់គ្នា មិនលែងឡើយនឹងរឹតតែគិតឃើញពី 「រូបគេរូបយើង,កូនគេកូនយើង」 , 「តើអ្វីដែលមិនចាំបាច់នឹងធ្វើអ្វី?」 「តើត្រូវពិចារណាជាថ្មីម្តងទៀតពីអ្វី?」 កាន់តែខ្លាំងឡើងៗ។

គ្រោះមហន្តរាយនៃកូវីដ-១៩នេះទោះបីជានៅប្រទេសជប៉ុន លែងសូវឆ្លងរាលដាលហើយ បានស្ងប់ខ្លះហើយក្តីក៏ដោយ ក៏នៅប្រទេសផ្សេងទៀតនៅតែមានឆ្លងរាតត្បាតនៅឡើយទេ។ យើងមិនអាចដឹងបានថាតើថ្ងៃណាវានឹងត្រឡប់មករាតត្បាតវិញឡើយ។

កវីនិពន្ធ មីយ៉ាសាវ៉ា គេនជី (1896-1933) បាននិយាយថា៖ នៅពេលដែលពិភពលោកទាំងមូលគ្មានសេចក្តីសុខ, បុគ្គលមួយរូបៗក៏គ្មានសេចក្តីសុខដែរ។ពាក្យមួយឃ្លានេះធ្វើឱ្យយើងដឹងច្បាស់ក្រឡែតតែម្តងនៅវេលានេះ។យើងអាចគិតបានថាពាក្យរបស់កវីនិ ពន្ធនេះគឺជាពាក្យដែលបង្ហាញនូវមហាមេត្តាករុណានៃព្រះពុទ្ធបែបសម័យទំនើបដែលយើងតោងតែយកមកពិចារណាមើល។

ឈរនៅលើទស្សនៈនេះខ្ញុំព្រះករុណាអាត្មាភាពបានដាក់ 「ទិសដៅឬមុខសញ្ញាទៅលើឆ្នាំ ២០២២」 ដូចតទៅនេះ៖

ចូលមកដល់ខែមីនាឆ្នាំនេះតាំងពីបង្កើតសមា គមរីស្សូកូសេកៃមក យើងចូលដល់ខួបគម្រប់ឆ្នាំទី៨៤ហើយៗតាំងពីខ្ញុំព្រះករុណាអាត្មាភាពឡើងធ្វើការងារបន្តពីកៃសូសាម៉ាមក,

រយៈពេល៣០ឆ្នាំបានកន្លងផុតទៅហើយ។

ឆ្នាំនេះក៏ខ្ញុំព្រះករុណាអាត្មាភាពគិតថាជីវភាពរស់នៅដោយកំណត់សកម្មភាពខ្លួនឯងនៅតែបន្តដដែលដូច្នេះក៏មិនដឹងដែរ។យើងតោងតែមើលស្ថានភាពឆ្លងនៃកូវីដ-១៩បណ្តើរៗហើយឆ្លងកាត់តាមជីវភាពដែលមានជំនឿទៅលើព្រះពុទ្ធសាសនានៃយើងទាំងអស់គ្នា អាត្មាភាពសូមឱ្យកុំភ្លេចពីសមានចិត្តគិតពីអ្នកដទៃ សូមបំពេញតួនាទីក្នុងនាមជាស្វាមីភរិយា,ក្នុងនាមជាមាតាបិតា,ក្នុងនាមជាអ្នកចាស់ទុំ,យើងតោងតែគិតពីការបណ្តុះបណ្តាលបុត្រធិតា, កុមារនិងយុវជនដែលកំពុងតែចងក្រងអត្តចរឹតខ្លួនគេដែលជាទំពាំងស្នងឬស្សីទ្រទ្រង់សង្គមបន្តវេនពីយើង, ត្រូវធ្វើយ៉ាងណារៀបចំគ្រួសារឱ្យមានសណ្តាប់ធ្នាប់ ហើយលើសពីនេះទៅទៀត តើត្រូវធ្វើយ៉ាងណាឱ្យអ្នកទាំងនេះបន្តទំនៀមទម្លាប់នៃប្រទេសជាតិរបស់ខ្លួនឈរលើស្មារតីសុខដុំរម្យនារិៈគិតបែបច្នៃប្រឌិតនិងឱ្យបានហ្មត់ចត់ដើម្បីកសាងប្រទេសជាតិដ៏ល្អប្រសើរមួយ។

ដូចដែលខ្ញុំព្រះករុណាអាត្មាភាពបាននិយាយតាមសារពីឆ្នាំមុនហើយថា 《ស្វាមីភរិយា》 ដែលអាត្មាភាពនិយាយនេះគឺសំដៅទៅលើគូស្វាមីភរិយាក្មេងៗ, 《ឪពុកម្តាយ》 គឺសំដៅទៅរកអ្នកមានវ័យច្រើនបន្តិចដែលកំពុងតែធ្វើការងារសស្រាក់សស្រាំ,រីឯអ្នកចាស់ទុំគឺអាត្មាភាពសំដៅទៅលើជំនាន់មនុស្សដែលមានអា យុចំណាស់មានបទពិសោធន៍ច្រើនក្នុងជីវិត ក្នុងន័យថាសូមឱ្យផ្ទេរបទពិសោធន៍ទាំង ឡាយទៅកូន,ទៅចៅដើម្បីចូលរួមចំណែកក្នុងការបណ្តុះបណ្តាលកុមារនិងយុវជនមួយជំនាន់ៗមិនត្រឹមតែក្នុងសមាគមរីស្សូកូសេកៃយើងតែប៉ុណ្ណោះទេ តែក្នុងសង្គមនិងប្រទេសជាតិទាំងមូលផងដែរ។

អ្វីដែលជាមូលដ្ឋានគឺការអប់រំនៅក្នុងគ្រួសារតែម្តង។នៅពេលដែលកុមារទទួលការអប់រំក្នុងគ្រួសារ ជាមនុស្សម្នា មានភាពថ្លៃថ្នូរដ៏ខ្ជាប់ខ្ជួនហើយ គេក៏អាចទទួលការអប់រំយ៉ាងពេញលេញពីសាលារៀន ហើយទាំងនេះបន្តផ្ជាប់ទៅនឹងន័យពិតប្រាកដនៃការ 《ដាំបណ្តុះមនុស្ស》 ។

បន្ទាប់មកអាត្មាភាពក៏បាននិយាយរួចហើយដែរថា នៅក្នុងការពិតជាក់ស្តែងការអប់រំនៅផ្ទះ

ដូចជាការ《ថ្វាយបង្គំព្រះពុទ្ធបដិមារជាប្រចាំ》និង《 កិច្ចប្រតិបត្តិបីយ៉ាង》 (ពេលព្រឹកត្រូវធ្វើគារវកិច្ចដាក់គ្នា, ពេលគេហៅចំឈ្មោះត្រូវឆ្លើយច្បាស់ៗថា 《បាទ》 ឬ《ចាស》, ពេលដោះស្បែកជើងត្រូវតម្រឹមតម្រង់ដាក់ផ្ទឹមគ្នាជាគូជាដើមជាការសំខាន់ខ្លាំងណាស់។យើងទាំងអស់គ្នាដែលជាសមា ជិកនៃរីស្ហូកូសេកៃ តែងតែចាត់ទុកកិច្ចប្រតិ
បត្តិទាំងអស់នេះជាសំខាន់ជានិច្ចជាកាល។

## ពលរដ្ឋម្នាក់ៗត្រូវតែមានសេចក្តីប្រាថ្នាអស់ពីជម្រៅចិត្តនិងទង្វើបែបច្នៃប្រឌិតថាត្រូវតែកសាងប្រទេសជាតិឱ្យទៅជាប្រទេសដ៏រឹងមាំ។

ក្រៅពីនេះពីលើ《មុខសញ្ញាដែលអាត្មាភាពដាក់សម្រាប់ឆ្នាំ២០២២》អាត្មាភាពបានបន្ថែមមួយឃ្លាទៀតថា ស្របជាមួយនឹងការបណ្តុះ
បណ្តាលកុមារតូចធំនិងយុវជនគឺធ្វើឱ្យអ្នកទាំងនោះ《ទទួលយកទំនៀមទម្លាប់បរមបុរាណរបស់ជាតិមាតុភូមិហើយបន្តដើម្បីធ្វើយ៉ាងណាឱ្យអាចកសាងប្រទេសជាតិឱ្យទៅជាប្រទេសរឹងមាំល្អបាន។》
នៅជំនាន់បុរាណជប៉ុនមានឈ្មោះថា《 យ៉ាម៉ាតូ 》ដែលមានន័យថា《មានសុខសន្តិភាពធំ
អស្ចារ្យ》 ឬក៏《ប្រកបទៅដោយភាពសុខដុំរម្យនាធំអស្ចារ្យ》។ថ្នាក់ដឹកនាំជប៉ុនតាំងពីជំនាន់នោះបានយកស្មារតីនោះមកធ្វើជាឧត្តមគតិជាតិរហូតរៀងមក។
ម្យ៉ាងទៀតព្រះអង្គម្ចាស់សូតុគឺថៃស៊ី (593- 622) បានដាក់ទៅក្នុងមាត្រាទី១៧រដ្ឋធម្មនុញ្ញបុរាណ(604)របស់លោកថា《នៅពេលដែលយើងមានភាពសុខដុំរម្យនា យើងនឹងថ្លៃថ្នូរ 》។ស្មារតីដែលមាននៅក្នុងពាក្យនេះមិនត្រឹមតែជាគម្រូសម្រាប់ការកសាងជាតិនៅជំនាន់នោះតែប៉ុណ្ណោះទេ ក៏ប៉ុន្តែវាចាក់ឫសជ្រៅទៅក្នុងសារធាតុនិងស្មារតីនៃជនជាតិជប៉ុនតែម្តង។
លើសពីនេះទៅទៀតទំនៀមទម្លាប់និងប្រវត្តិ សាស្ត្រដែលជាលក្ខណៈពិសេសរបស់ជប៉ុនគឺកើតឡើងដោយសារមានរបបព្រះចៅអធិ
រាជ។ព្រះចៅអធិរាជជប៉ុនគ្មាននាមត្រកូលដែលបញ្ជាក់នូវភាពបុគ្គលឡើយ។គឺជាការបង្ហាញឱ្យឃើញថាព្រះរាជវង្សជប៉ុនតែងតែនៅជាប់ជាមួយនឹងប្រជាជនរហូតមកហើយ។
តាំងពីកំណកំណើតនៃប្រទេសជប៉ុនមក ទោះជាជនជាតិជប៉ុនបានជួបប្រទះនឹងបញ្ហាជាច្រើនរាប់មិនអស់ក៏ដោយ ក៏ជនជាតិជប៉ុនអាចកសាងបង្កើតវប្បធម៌ដ៏សម្បូរសប្បាយព្រមទាំងទំនៀមទម្លាប់ប្រកបដោយលក្ខណៈពិសេសមកបាននេះគឺដោយសារតែនៅគ្រប់ ៗជំនាន់មានព្រះចៅអធិរាជជាសរសរស្តម្ភទ្រទ្រង់ហើយប្រជាជនជប៉ុនខិតខំព្យាយាមរួមកម្លាំងគ្នាជាធ្លុងមួយ នៅក្រោមម្លប់នោះប្រកបដោយ《ភាពសុខដុំរម្យនា》នោះឯង។
ក៏ប៉ុន្តែលុះដល់ក្រោយសង្គ្រាម ជប៉ុនបែរជាទៅស្វែងរកផលចំណេញខាងសេដ្ឋកិច្ចនិងភាពសមហេតុសមផលពេកទៅ ជប៉ុនក៏ទៅជាបំភ្លេចប្រវត្តិសាស្ត្រ,ទំនៀមទម្លាប់និងស្មារ តីដែលបានកសាងមកហើយ។
សព្វថ្ងៃនេះបើយើងបំបែរភ្នែកមើលទៅពិភពលោក យើងនឹងឃើញថាប្រទេសនីមួយៗគិតតែពីផលប្រយោជន៍ប្រទេសរបស់ខ្លួន។នៅឱកាសបែបនេះ ជប៉ុនមានតួនាទីច្រើនយ៉ាងដែលត្រូវបំពេញដោយពង្រស់ស្មារតី《សុខដុំរម្យនា》 ដែលមាននៅក្នុងទំនៀមទម្លាប់របស់ខ្លួន។
ដើម្បីនឹងឱ្យអាចធ្វើដូច្នេះបាន យើងតោងតែធ្វើឱ្យប្រទេសយើងរឹងមាំខ្ជាប់ខ្ជួនសិន ។សេចក្តីប្រាថ្នានិងសកម្មភាពថាត្រូវតែកសាងប្រទេ សឱ្យបានប្រសើរមាំមួននោះទាមទារឱ្យប្រជាជនម្នាក់ៗបើកបេះដូងឱ្យកាន់តែទូលាយ ធ្វើសកម្មភាពដោយភាពឆ្នៃប្រឌិតនិងដោយប្រាកដប្រជាពីជម្រៅចិត្ត មិនត្រូវរំពឹងតែទៅលើអ្នកនយោបាយតែម្យ៉ាង នោះឡើយ។
ដូចដែលខ្ញុំព្រះករុណាអាត្មាភាពបានដាក់ព្រួញសញ្ញាជំនឿហើយ ថ្ងៃទី១៥ខែវិច្ឆិកាឆ្នាំមុន រីស្ហូកូសេកៃយើងតាំងពីខ្ញុំព្រះករុណាអាត្មាភាពឡើងធ្វើការងារបន្តពីកៃសូសាម៉ាមករយៈពេល៣០ឆ្នាំបានកន្លងផុតទៅហើយ។ពិតជាឆាប់មែនទែន។

## យើងមានពាក្យទំនៀមថា 《ភ្នូររាស់ស្រែបេះដូង 》។ពាក្យនេះគឺមានន័យថា ស្គាល់ខ្លួនឯងច្បាស់ពិតប្រាកដ។

តាំងពីខ្ញុំព្រះករុណាឡើងធ្វើការងារបន្តពីកៃសូសាម៉ាមកខ្ញុំព្រះករុណាអាត្មាភាពបាននិយាយថាយើងទាំងអស់គ្នា《តម្រៀបជួរគ្នាមួយជួរទៅខាងចំហៀងគ្មានលើគ្មានក្រោម រួមកម្លាំងគ្នាជាធ្លុងមួយហើយចេញដំណើរជាមួយគ្នា》។

សមាជិកនៃសមាគមរីស្សូកូសេកៃយើងម្នាក់ៗសុទ្ធតែមានភាពជាព្រះពុទ្ធស្មើៗគ្នា។ខ្ញុំព្រះករុណាអាត្មាភាពក៏ដូចជាអ្នកទាំងអស់គ្នាដែរ ក្នុងនាមជាព្រះពោធិសត្វមួយអង្គ ខ្ញុំព្រះករុ ណាអាត្មាភាពនឹងដើរតាមមាគ៌ាព្រះពុទ្ធ។សេចក្តីបំណងនោះខ្ញុំព្រះករុណាបង្កប់នៅក្នុងសារនេះ។

ម្យ៉ាងទៀតនៅឆ្នាំបន្ទាប់ដែលខ្ញុំព្រះករុណាអាត្មាភាពបានបន្តការងារពីកៃសូសាម៉ា គឺនៅឆ្នាំ ១៩៩២ ខ្ញុំព្រះករុណាអាត្មាភាពបានទទួលឱកាស《ដើរសួរសុខទុក្ខញាតិ》ដោយទៅជួបបរិស័ទទាំងឡាយនៅគ្រប់១៣០ព្រះវិហារទូទាំងប្រទេស ។

នៅក្នុងជីវភាពរស់នៅរាល់ថ្ងៃ,នរណាម្នាក់ក៏មានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក ពឹងពាក់គ្នាទៅវិញទៅមក ទទួលឥទ្ធិពលពីគ្នាទៅវិញទៅមកដែរ។

បើនិយាយក្នុងន័យធំទូលំទូលាយទៅ នៅក្នុងច័ក្រវាលទាំងមូលនេះ យើងទាំងឡាយសុទ្ធតែជាសាច់ញាតិសន្តាននឹងគ្នា។នៅក្នុងចំណោមនោះ អ្នកដែលជិតស្និទ្ធជាងគេបំផុតគឺញាតិសន្តានដែលយល់ចិត្តគ្នា គឺគ្មាននរ ណាក្រៅពីបរិស័ទនេះទេ។ដូច្នេះហើយទើបបានជាខ្ញុំព្រះករុណាអាត្មាភាពប្រើពាក្យថា 《ដើរសួរសុខទុក្ខញាតិ》នោះ។

នៅពេលដែលឮខ្ញុំព្រះករុណាអាត្មាភាពប្រើពាក្យថា 《ដើរសួរសុខទុក្ខញាតិ》កៃសូសាម៉ាបានមានសង្ឃដីកាថា ៖ 「ពាក្យថាញាតិពិតជាពិរោះមែន」។រួចហើយព្រះអង្គរីករាយហាឫទ័យជាអនេក។ទ្រង់បានមានសង្ឃដីកាថា៖「ថ្មីៗនេះ នីជីកុសប្បាយចិត្តនឹងទៅព្រះវិហារណាស់」។រួចហើយបន្តមានសង្ឃដីកាកំប្លែងថា៖「បើដឹងអ៊ីចឹងប្រគល់ឱ្យបន្តតំណែងតាំងពីយូរយារណាស់ហើយបាត់។」

ក៏ប៉ុន្តែនៅពេលដែលខ្ញុំព្រះករុណាអាត្មាភាពទទួលតំណែងបន្តបាន៨ឆ្នាំ នៅថ្ងៃទី៤ខែតុលាឆ្នាំ២០០០កៃសូសាម៉ាក៏ទទួលអនិច្ចធម្មទៅនាព្រះជន្មាយុ៩២ព្រះវស្សា។មុនដែលទ្រង់ទទួលអនិច្ចធម្ម ឱ្យតែមានអ្វីបន្តិច ខ្ញុំព្រះករុណាអាត្មាភាពតែងតែរត់ទៅរកព្រះអង្គឱ្យជួយដោះស្រាយ។មរណធម្មរបស់ព្រះអង្គហាក់ដូចជាជម្រុញយើងឱ្យអាចដោះស្រាយបញ្ហាដោយខ្លួនឯង។

ខ្ញុំព្រះករុណាអាត្មាភាពនឹងអធិប្បាយពីសេចក្តីបង្រៀនប្រៀនប្រដៅរបស់កៃសូសាម៉ាត្រួសៗ។គឺថាត្រូវមានកត្តញ្ញូកត្តវេទីចំពោះឪពុកម្តាយ គោរពបូជាដូនតា និងបតិបត្តិទង្វើព្រះពោធិសត្វ។ទាំងនេះខ្ញុំព្រះករុណាអាត្មាភាពតែងតែជម្រាបមកជារឿយៗហើយ។

ជាពិសេសកិច្ចប្រតិបត្តិព្រះពោធិសត្វគឺជា

ទង្វើដែលប្រព្រឹត្តទៅតាមគន្លងព្រះធម៌។យើងគោងតែបង្កទឹកចិត្តជាព្រះពោធិសត្វរួចហើយដើរតាមមាគ៌ាព្រះពោធិសត្វ។បើនិយាយឱ្យងាយយល់គឺមានមេត្តាករុណា និងសមានចិត្ត។នេះគឺអ្វីដែលកៃសូសាម៉ាប៉ងប្រាថ្នា។

ថ្មីៗនេះបរិស័ទដែលធ្លាប់បានទទួលសេចក្តីទូន្មានប្រៀនប្រដៅផ្ទាល់ពីកៃសូសាម៉ាកាន់តែតិចទៅៗហើយ។មនុស្សជាច្រើនបានទទួលបទពិសោធន៍ថាបានភ្ញាក់ខ្លួននិងបានទទួលការស្រោចស្រង់ឆ្លងកាត់តាមដំបូន្មាននិងការណែនាំរបស់ព្រះអង្គ ។ ខ្ញុំព្រះករុណាអាត្មាភាពមានសំណូមពរសូមឱ្យលោកអ្នកទាំងនោះ លើកយកបទពិសោធន៍នោះមកបង្ហាញឱ្យបានដឹងច្រើនគ្នាបន្តទៀត។

ក្រោយពីបានបន្តវេនពីកៃសូសាម៉ាមក អ្វីដែលខ្ញុំព្រះករុណាអាត្មាភាពចង់ជំរាបលោកអ្នកទាំងអស់បំផុតនោះគឺថា ការពិភាក្សាពីមនុស្ស ឬពីសង្គម ជាការងាយស្រួលទេ ក៏ប៉ុន្តែអ្វីដែលសំខាន់គឺការសង្កេតមើលមកខ្លួនឯងហើយស្គាល់ខ្លួនឯងឱ្យច្បាស់ឯនោះទេ។

ចុះធ្វើដូចម្តេចទៅឱ្យអាចស្គាល់ខ្លួនឯងនោះ?ខ្ញុំព្រះករុណាបានគិតពីរឿងនេះ ហើយទើប

តែនឹងបានរកឃើញចម្លើយនៅពេលខួបគម្រប់៦០ឆ្នាំនៃសមាគមរីស្ហូកូសេកៃយើងតែប៉ុណ្ណោះថាមានតែ 《ភ្ជួររាស់ស្រែចិត្ត》 តែប៉ុណ្ណោះ ។

ហើយនោះគឺជាគោលដៅដែលខ្ញុំព្រះករុណាអាត្មាភាពបានដាក់សម្រាប់ឱ្យខ្លួនឯងដើរសំដៅទៅរក។ ( 《ស្រែចិត្ត》 គឺមានន័យថាបេះដូងយើងនោះគឺជាស្រែ។គឺជាស្រែដែលយើងអាចសាបព្រោះពូជព្រះពុទ្ធយ៉ាងងាយ។) សព្វថ្ងៃនេះក៏ខ្ញុំព្រះករុណាអាត្មាភាពដើរជាមួយនឹងអ្នកទាំងអស់គ្នាជាបរិស័ទដែរ។

មនុស្សភាគច្រើនតែងតែគិតយ៉ាងរឹងរូសថាខ្លួនដែលមានកំណត់នោះ 《គឺខ្លួនឯង》 ហើយក៏តាំងទៅជាមានការតូចចិត្ត ឬក៏ផ្ទុយទៅវិញទៅជាឡឺត ហើយក្អេងក្អាង ។តើនោះពិតជាខ្លួនឯងពិតប្រាកដមែនឬទេ?

ព្រះពុទ្ធជាម្ចាស់ក្នុងនាមជាមនុស្សលោក ។ មានសេចក្ដីកង្វល់ មានក្ដីបារម្ភ ហើយចុងបញ្ចប់ក៏បានត្រាស់ដឹងពីសច្ចធម៌ ពីព្រះធម៌។ដូច្នេះយើងដែលជាមនុស្សដូចព្រះអង្គដែរ យើងត្រូវតែមានលត្ថភាពអាចទទួលដឹងសច្ចធម៌ និងព្រះធម៌ហើយមានប្រាជ្ញាអាចដោះស្រាយបញ្ហារបស់ខ្លួនដោយខ្លួនឯងដូចតែព្រះអង្គដែរ។

នៅពេលដែលយើងស្គាល់ច្បាស់ថាខ្លួនយើងយ៉ាងដូចម្ដេចហើយយើងក៏អាចជម្នះលើបញ្ហានានាដែលនៅពីមុខយើងបាន ហើយនោះគឺជាការចាប់ផ្ដើមនៃជីវិតដ៏មានន័យខ្លឹមសារ។

ដូច្នេះ 《ភ្ជួររាស់ស្រែចិត្ត》 គឺគ្មានអ្វីក្រៅពីស្គាល់ខ្លួនឯងច្បាស់នោះឡើយ។សំខាន់គឺខ្លួនឯងដែលរស់នៅក្នុងលោកសព្វថ្ងៃនេះមានបេះដូងដូចតែព្រះពុទ្ធព្រះបរមគ្រូនៃយើងដែរ ហើយចាប់ភ្លឹកថាមានសមត្ថភាពនិងទំនួលខុសត្រូវក្នុងការដោះស្រាយបញ្ហាជីវិតខ្លួនឯងនិងបញ្ហាពិភពលោក ។

តាំងពីខ្ញុំព្រះករុណាអាត្មាភាពទទួលវេនបន្តជាប្រធាននៃសមាគមរីស្ហូកូសេកៃជំនួសកៃស្សាម៉ាមក រយៈពេល៣០ឆ្នាំបានកន្លងទៅហើយ ។បរិស័ទដែលយល់ពីបញ្ហានេះហើយប្រកបជីវភាពស្រស់ស្រាយមានទឹកដម បានកើនច្រើនឡើងៗ ហើយអ្នកដែលមិនទាន់ចាប់ភ្លឹកពីខ្លួនឯងក៏នៅមានច្រើនដែរ។

លើសពីនេះទៅទៀតខ្ញុំព្រះករុណាអាត្មាភាពប្រាថ្នាសូមឱ្យសមាជិកម្នាក់ៗនៃរីស្ហូកូសេកៃយើង ធ្វើយ៉ាងណាណែនាំមនុស្សម្នាទាំង ឡាយបន្ត ដើម្បីឱ្យស្មារតីនៃព្រះធម៌ព្រះពុទ្ធរស់រវើកទៅជាសកម្មភាពពិតៗមិនមែនត្រឹមតែជាព្រះធម៌ដែលគ្រាន់តែសូត្ររត់មាត់។

ឆ្នាំថ្មីនេះក៏គ្រោះមហន្តរាយកូវីដ-១៩នៅបន្តហើយសកម្មភាពផ្សព្វផ្សាយព្រះធម៌ក៏មិនអាចប្រព្រឹត្តទៅដោយរលូនបានទេក៏មិនដឹង ក៏ប៉ុន្តែតោងតែព្យាយាម ថានៅទីណាក៏ជាព្រះវិហារសម្រាប់ប្រតិបត្តិព្រះធម៌ ទីដែលអ្នកកំពុងនៅគឺជាទីកន្លែងរកមាគាព្រះធម៌ ហើយស្រឡាញ់គេហដ្ឋាន គ្រួសារដែលជាសង្គមតូចបំផុត អភិវឌ្ឍខ្លួនជាមួយនឹងយុវជននិងកុមារដែលជាទំពាំងស្នងឫស្សី។

# Rissho Kosei-kai: A Global Buddhist Movement




**Rissho Kosei-kai Buddhist Church of Hawaii**
2280 Auhuhu Street, Pearl City, HI 96782, USA
TEL: 1-808-455-3212 FAX: 1-808-455-4633
Email: sangha@rkhawaii.org URL: http://www.rkhawaii.org

**Rissho Kosei-kai Maui Dharma Center**
1809 Nani Street, Wailuku, HI 96793, USA
TEL: 1-808-242-6175 FAX: 1-808-244-4625

**Rissho Kosei-kai Kona Dharma Center**
73-4592 Mamalahoa Highway, Kailua-Kona, HI 96740, USA
TEL: 1-808-325-0015 FAX: 1-808-333-5537

**Rissho Kosei-kai Buddhist Center of Los Angeles**
2707 East First Street, Los Angeles, CA 90033, USA
POBox 33636, CA 90033, USA
TEL: 1-323-269-4741 FAX: 1-323-269-4567
Email: rk-la@sbcglobal.net URL: http://www.rkina.org/losangeles.html

Please contact Rissho Kosei-kai Buddhist Center of Los Angeles
**Rissho Kosei-kai Buddhist Center of Arizona**
**Rissho Kosei-kai Buddhist Center of Colorado**
**Rissho Kosei-kai Buddhist Center of San Diego**
**Rissho Kosei-kai Buddhist Center of Las Vegas**
**Rissho Kosei-kai Buddhist Center of Dallas**

**Rissho Kosei-kai of San Francisco**
1031 Valencia Way, Pacifica, CA 94044, USA
POBox 778, Pacifica, CA 94044, USA
TEL: 1-650-359-6951 Email: info@rksf.org

Please contact Rissho Kosei-kai of San Francisco
**Rissho Kosei-kai of Sacramento**
**Rissho Kosei-kai of San Jose**

**Rissho Kosei-kai of New York**
320 East 39th Street, New York, NY 10016, USA
TEL: 1-212-867-5677 Email: rkny39@gmail.com URL: http://rk-ny.org

**Rissho Kosei-kai of Chicago**
1 West Euclid Ave., Mt. Prospect, IL 60056, USA
TEL: 1-773-842-5654
Email: murakami4838@aol.com URL: http://rkchi.org

**Rissho Kosei-kai of Fort Myers**
URL: http://www.rkftmyersbuddhism.org

**Rissho Kosei-kai Dharma Center of Oklahoma**
2745 N.W. 40th St., Oklahoma City, OK 73112, USA
POBox 57138, Oklahoma City, OK 73157, USA
TEL: 1-405-943-5030 FAX: 1-405-943-5303
Email: rkokdc@gmail.com URL: http://www.rkok-dharmacenter.org

**Rissho Kosei-kai Dharma Center of Denver**
1255 Galapago St. #809 Denver, CO 80204, USA
TEL: 1-303-446-0792

**Rissho Kosei-kai Dharma Center of Dayton**
617 Kling Drive, Dayton, OH 45419, USA
URL: http://www.rkina-dayton.com

**The Buddhist Center Rissho Kosei-kai International of North America (RKINA)**
2707 East First St., Suite #1, Los Angeles, CA 90033, USA
TEL: 1-323-262-4430 FAX: 1-323-269-4567
Email: dharmasa@rksabuddhistcenter.org
URL: http://rksabuddhistcenter.org

**Rissho Kosei-kai Buddhist Center of San Antonio**
(Address) 6083 Babcock Road, San Antonio, TX 78240, USA
(Mail) POBox 692148, San Antonio, TX 78249, USA
TEL: 1-210-558-4430 FAX: 1-210-696-7745
Email: dharmasanantonio@gmail.com
URL: http://www.rkina.org/sanantonio.html

**Rissho Kosei-kai of Seattle's Buddhist Learning Center**
28621 Pacific Highway South, Federal Way, WA 98003, USA
TEL: 1-253-945-0024 Email: rkseattlewashington@gmail.com
URL: http://buddhistlearningcenter.org

**Rissho Kosei-kai of Vancouver**
Please contact RKINA

**Risho Kossei-kai do Brasil**
Rua Dr. José Estefno 40, Vila Mariana, São Paulo-SP, CEP 04116-060, Brasil
TEL: 55-11-5549-4446, 55-11-5573-8377
Email: risho@rkk.org.br URL: http://www.rkk.org.br

**Risho Kossei-kai de Mogi das Cruzes**
Av. Ipiranga 1575-Ap 1, Mogi das Cruzes-SP, CEP 08730-000, Brasil

**在家佛教韓国立正佼成会**
〒 04420 大韓民国 SEOUL 特別市龍山區漢南大路 8 路 6-3
6-3, 8 gil Hannamdaero Yongsan gu, Seoul, 04420, Republic of Korea
TEL: 82-2-796-5571 FAX: 82-2-796-1696

**在家佛教韓国立正佼成会釜山支部**
〒 48460 大韓民国釜山廣域市南區水營路 174, 3F
3F, 174 Suyoung ro, Nam gu, Busan, 48460, Republic of Korea
TEL: 82-51-643-5571 FAX: 82-51-643-5572

**社團法人在家佛教立正佼成會**
台湾台北市中正區衡陽路 10 號富群資訊大厦 4 樓
4F, No. 10, Hengyang Road, Jhongjheng District, Taipei City 100, Taiwan
TEL: 886-2-2381-1632, 886-2-2381-1633 FAX: 886-2-2331-3433

**台南市在家佛教立正佼成會**
台湾台南市東区崇明 23 街 45 號
No. 45, Chongming 23rd Street, East District, Tainan City 701, Taiwan
TEL: 886-6-289-1478 FAX: 886-6-289-1488
Email: koseikaitainan@gmail.com

**Rissho Kosei-kai South Asia Division**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8141 FAX: 66-2-716-8218

**Rissho Kosei-kai of Kathmandu**
Ward No. 3, Jhamsikhel, Sanepa-1, Lalitpur, Kathmandu, Nepal

**Rissho Kosei-kai of Kolkata**
E-243 B. P. Township, P. O. Panchasayar, Kolkata 700094, India

**Rissho Kosei-kai of Kolkata North**
AE/D/12 Arjunpur East, Teghoria, Kolkata 700059,
West Bengal, India

**Rissho Kosei-kai of Bodhgaya Dharma Center**
Ambedkar Nagar, West Police Line Road, Rumpur, Gaya-823001,
Bihar, India

**Rissho Kosei-kai of Patna Dharma Center**
Please contact Rissho Kosei-kai of Kolkata

**Rissho Kosei-kai of Central Delhi**
77 Basement D.D.A. Site No. 1, New Rajinder Nagar,
New Delhi 110060, India

**Rissho Kosei-kai of Singapore**
Please contact Rissho Kosei-kai International

**Rissho Kosei-kai of Phnom Penh**
W.C. 73, Toul Sampaov Village, Sangkat Toul Sangke, Khan Reouseykeo,
Phnom Penh, Cambodia

**RKISA Rissho Kosei-kai International of South Asia**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8141 FAX: 66-2-716-8218

**Rissho Kosei-kai of Bangkok**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8216 FAX: 66-2-716-8218 Email: info.thairissho@gmail.com

**Rissho Kosei Dhamma Foundation**
No. 628-A, Station Road, Hunupitiya, Wattala, Sri Lanka
TEL: 94-11-2982406 FAX: 94-11-2982405

**Rissho Kosei-kai of Polonnaruwa**
Please contact Rissho Kosei Dhamma Foundation

**Rissho Kosei-kai Bangladesh**
85/A Chanmari Road, Lalkhan Bazar, Chittagong, Bangladesh
TEL: 880-2-41360470

**Rissho Kosei-kai Mayani**
Mayani Barua Para, Mirsarai, Chittagong, Bangladesh

**Rissho Kosei-kai Damdama**
Damdama Barua Para, Mirsarai, Chittagong, Bangladesh

**Rissho Kosei-kai Satbaria**
Village: Satbaria Bepari Para, Chandanaih, Chittagong, Bangladesh

**Rissho Kosei-kai Chendhirpuni**
Village: Chendhirpuni, P.O.: Adhunogar, P.S.: Lohagara, Chittagong,
Bangladesh

**Rissho Kosei-kai Raozan**
Dakkhin Para, Ramzan Ali Hat, Raozan, Chittagong, Bangladesh

**Rissho Kosei-kai Laksham**
Village: Dhupchor, Laksham, Comilla, Bangladesh

**Rissho Kosei-kai Dhaka**
408/8 DOSH, Road No 7 (West), Baridhara, Dhaka, Bangladesh

**Rissho Kosei-kai Cox's Bazar**
Ume Burmize Market, Tekpara, Sadar, Cox's Bazar, Bangladesh

Please contact Rissho Kosei-kai Bangladesh
**Rissho Kosei-kai Patiya**
**Rissho Kosei-kai Ramu**
**Rissho Kosei-kai Aburkhiln**

**Buddiyskiy khram "Lotos"**
4 Gruzinski Alley, Yuzhno-Sakhalinsk 693005, Russia
TEL: 7-4242-77-05-14

**Rissho Kosei-kai of Hong Kong**
Flat D, 5/F, Kiu Hing Mansion, 14 King's Road, North Point, Hong Kong, China

**Rissho Kosei-kai Friends in Shanghai**

**Rissho Kosei-kai of Ulaanbaatar**
(Address) 15F Express Tower, Peace avenue, khoroo-1, Chingeltei district,
Ulaanbaatar 15160, Mongolia
(Mail) POBox 1364, Ulaanbaatar-15160, Mongolia
TEL: 976-70006960 Email: rkkmongolia@yahoo.co.jp

**Rissho Kosei-kai of Erdenet**
Please contact Rissho Kosei-kai International

**Rissho Kosei-kai di Roma**
Via Torino, 29, 00184 Roma, Italia
TEL/FAX: 39-06-48913949 Email: roma@rk-euro.org

Please contact Rissho Kosei-kai di Rome
**Rissho Kosei-kai of Paris**
**Rissho Kosei-kai of Venezia**

**Rissho Kosei-kai of the UK**
29 Ashbourne Road, London W5 3ED, UK
TEL: 44-20-8933-3247 Email: info@rkuk.org URL: https://www.rkuk.org
Facebook: https://www.facebook.com/rkuk.official
Twitter: https://twitter.com/rkuk_official
Instagram: https://www.instagram.com/rkuk_official

**Rissho Kosei-kai International Buddhist Congregation (IBC )**
166-8537 東京都杉並区和田 2-7-1 普門メディアセンター 3F
Fumon Media Center 3F, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan
TEL: 03-5341-1230 FAX: 03-5341-1224 URL: http://www.ibc-rk.org

**Published by Rissho Kosei-kai International**